**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខ:១៨៤
ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៩

<u>សាលដីកា</u>
លេខ:២១៦
ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៩

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៩ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម **ឌិត មុន្ទី** ជាប្រធាន
២-លោក **ប៉ែន ស៊ុន** ជាចៅក្រម
៣-លោក **វៀល មួន** ជាចៅក្រម
៤-លោក **ជីវ កេង** ជាចៅក្រម
៥-លោក **ឈឹម ស៊ីផល** ជាចៅក្រមរបាយការណ៍

<u>**ក្រឡាបញ្ជី**</u>
-លោកស្រី **អ៊ួង ឡានី**

<u>**តំណាងមហាអយ្យការ**</u>
-លោក **ជួន ស៊ុនឡេង** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ៨៦ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៣៨០ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ដូ ណាណា ភេទប្រុស អាយុ៤៦ឆ្នាំ ជាតិខ្មែរ មុខរបរពាណិជ្ជករ ទីលំនៅផ្ទះលេខ ២០១BE1 ផ្លូវម៉ៅសេទុង សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

មានមេធាវីលោក សោម ច័ន្ទឌីណា ជាតំណាង

និងចុងបណ្តឹងសាទុក្ខឈ្មោះសេង យៀន ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ មុខរបរគ្រូបង្រៀន ទីលំនៅផ្ទះលេខ ៤០២E0 សង្កាត់មិត្តភាព ខណ្ឌ៧មករា ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ឈុន សេង(ស) ម្តាយឈ្មោះ ហង្ស ឡាយ (រ) ។

<u>**កម្មវត្ថុបណ្តឹង**</u> ៖ ប្តឹងសុំឱ្យគោរពកិច្ចសន្យា និង ទារសំណងបង់ខាត

បានឃើញបណ្តឹងសាទុក្ខលេខ ៩៦ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៩៩ របស់លោក ដូ ណាណា បានប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចនៃសាលដីកាលេខ៨៦ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៤៤ ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ១៩៩៩ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី ០៣-៥-៩៨ របស់ឈ្មោះសេង ឃៀន ជាដើមចោទថា : ខ្លួនសុំប្ដឹងពីឈ្មោះដូ ណាណា ដែលមិនគោរពកិច្ចសន្យារវាងក្រុមហ៊ុន ស្ដារប៊ីយូធី STAR BEAUTY និងរោងទឹកអប់៤០២ ជូលីម៉ាដាម JOLIE MADAME ដោយទាមទារកាបង់ខាតចំនួន ៣៣.០៣៣ដុល្លា និងប្រាក់ជម្ងឺចិត្តចំនួន ៨.០០០ដុល្លា ដោយសំអាងហេតុថាឈ្មោះដូ ណាណា ដែលជាម្ចាស់ភាគហ៊ុននៃក្រុមហ៊ុន STAR BEAUTY រួមមានឈ្មោះតុង ហួត, ដូ ណាណា និងឈ្មោះជា លីម បាននាំមុខទំនិញម៉ាក្យ ARNAUD ចំនួន១២ប្រភេទផ្ដាច់មុខពីប្រទេសបារាំង ដោយចុះកិច្ចសន្យាឲ្យហាងទឹកអប់ ៤០២ JOLIE MADAME លក់ផ្ដាច់នៅក្នុងស្រុកខ្មែរ ។ ក្រោយពីខ្លួនបានរៀបចំផ្សាយពាណិជ្ជកម្ម និងធ្វើចរាចរទំនិញនៅលើទីផ្សារហើយ ស្រាប់តែនៅថ្ងៃទី ១៥-១២-៩៧ ឈ្មោះដូ ណាណា បានរៀបចំល្បិចបង្កើតក្រុមហ៊ុនមួយទៀត ដែលមានឈ្មោះហៅថា HEALTH BEAUTY ដើម្បីលួចនាំមុខទំនិញ ARNAUD ចូលមកលក់ពេញទីផ្សារ នៃព្រះរាជាណាចក្រកម្ពុជា ដោយផ្ទាល់ធ្វើឱ្យខ្លួនបាត់បង់នូវប្រយោជន៍ជាច្រើន ។

បានឃើញសាលក្រមលេខ៨២(ក) ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១- ទទួលពាក្យបណ្ដឹងរបស់ដើមចោទឈ្មោះ សេង ឃៀន ចុះថ្ងៃទី០៣-០៥-៩៨ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ និងពាក្យសុំមេធាវី ចុះថ្ងៃទី ០២-០៦-៩៨ របស់ឈ្មោះដូ-ណាណា ឱ្យមេធាវី សោម ច័ន្ទឌីណា ដើម្បីធ្វើជាអ្នកតំណាងសិទ្ធិ និង ជាមេធាវីឱ្យខ្លួនទៅតុលាការទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៣- បង្គាប់ឱ្យឈ្មោះដូ ណាណា ភេទប្រុសអាយុ៤៦ឆ្នាំ ដែលមានលោកសោម ចន្ទ័ឌីណា ជាអ្នកតំណាងសិទ្ធិ និងជាមេធាវី និងក្រុមហ៊ុន STAR BEAUTY ដែលមានឈ្មោះតុង ហួត ជាប្រធានឱ្យគោរពកិច្ចសន្យា ចុះថ្ងៃទី០៦-០៣-៩៧ រវាងក្រុមហ៊ុន STAR BEAUTY និងហាងទឹកអប់ ៤០២ JOLIE MADAME ដែលមានម្ចាស់ឈ្មោះ សេង ឃៀន ឡើងវិញ ។

៤- បង្គាប់ឱ្យភាគីចុងចម្លើយឈ្មោះដូ ណាណា ឈ្មោះតុង ហួត ជាប្រធានក្រុមហ៊ុនSTAR BEAUTY សងការខាតបង់ជាប្រាក់ចំនួន ៣៣.០៣៣ ដុល្លាអាមេរិក (បីម៉ឺនបីពាន់សាមសិបបីដុល្លាអាមេរិក) ប្រាក់ជម្ងឺចិត្តចំនួន៥.០០០ ដុល្លាអាមេរិក(ប្រាំពាន់ដុល្លាអាមេរិក) ឱ្យទៅដើមចោទឈ្មោះសេង ឃៀនភេទប្រុសអាយុ ៣៩ឆ្នាំ ចាប់ពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ ។ ការទាមទារលើសពីនេះបដិសេធ

ចោល ក្នុងករណីឈ្មោះដូ ណាណា និង ឈ្មោះតុង ហួត រឹងទទឹងមិនព្រមសងប្រាក់គ្រប់ចំនួនឱ្យទៅដើម-ចោទទេ សម្រេចរឹបអូសលក់ឡាយឡុងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន STAR BEAUTY និងទ្រព្យសម្បត្តិរបស់ភាគីចុងចម្លើយឈ្មោះដូ ណាណា ឈ្មោះតុង ហួត ជាប្រធានក្រុមហ៊ុនSTAR BEAUTY ដើម្បីជានាសំណង និង សម្រេចដាក់គុកបង្ខំរូបកាយលើឈ្មោះដូ ណាណា កំណត់៨ខែ (ប្រាំបីខែ) តាមមាត្រា១៣៣ នៃច្បាប់ស្តីពីនីតិវិធីអនុវត្តន៍សាលក្រមរដ្ឋប្បវេណី ។

៥- បង្គាប់ឱ្យភាគីចុងចម្លើយឈ្មោះ ដូណាណា និង ឈ្មោះតុង ហួត បង់ប្រាក់ប្រដាប់ក្តីចំនួន ៧.០០០រៀល គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ១.៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រៀល ប្រាក់នេះដើមចោទបានបង់រួចហើយ ។ កាលបើហួសបណ្តឹងឧទ្ធរណ៍បង្គាប់ឱ្យភាគីចុងចម្លើយឈ្មោះ ដូ ណាណា និង ឈ្មោះ តុង ហួត សងប្រាក់ចំនួន ៧.០០០រៀល នេះ ទៅដើមចោទវិញ និងបង្គាប់ ឱ្យបង់ពន្ធសមាមាត្រចំនួន១ភាគរយ លើទឹកប្រាក់ទាំងអស់ដែលចុងចម្លើយត្រូវសងឱ្យដើមចោទ ។

៦- សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ ចំពោះមុខមេធាវីតំណាងសិទ្ធិរបស់ចុងចម្លើយ សម្រេចបើកផ្លូវឧទ្ធរណ៍ ក្នុងកំណត់ច្បាប់គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៦២(ក) ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៩៨ របស់លាកសោម ច័ន្ទឌីណា ដែលប្តឹងជំទាស់នឹងសាលក្រមលេខ ៨២(ក) ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៨៦ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៦២(ក) ចុះថ្ងៃទី១២-៨-១៩៩៨ របស់លាកសោម ច័ន្ទឌីណា ថណាយក្តីឱ្យភាគីចុងចម្លើយ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលដោយទាស់នឹងគតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៨២(ក) ចុះថ្ងៃទី២២-៧-១៩៩៨ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយគឺៈ ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់៤៥០រៀល ចំណាយលើកិច្ចប្រ-គល់ដីកាកោះ ៥.០០០រៀល ចំណាយលើអាជ្ញាធរតុលាការ ៥.០០០រៀល សរុប ១៣.០០០រៀល ។

៤- សាលដីកានេះ ជំនុំជំរះនាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៩ ចំពោះមុខគូក្តី និងប្រកាសជាសាធារ-ណៈ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៩៩ ចំពោះមុខក្តី បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៩៦ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៩៩ របស់លោកដូ ណាណា បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ៨៦ ចុះថ្ងៃទី ២៦ ខែកុម្ភៈឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍លើ

សេចក្តីសម្រេចទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី០៦-៦-៩៩ របស់ឈ្មោះដូ ណាណា តំណាងដោយលោក មេធាវី សោម ច័ន្ទឌីណា ។

បានឃើញសារណាតប ចុះថ្ងៃទី២៦-៧-៩៩ របស់ឈ្មោះសេង យៀន ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ :

-ក្រោយពីបានពិនិត្យ លើសាលដីការដ្ឋប្បវេណីលេខ ៨៦ ចុះថ្ងៃទី ២៦-០២-៩៩ របស់សាលាឧទ្ធរណ៍ ដែលសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ហើយ ។

-អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិចារណាតាមច្បាប់តទៅ ។

ក្រឡាបញ្ជីឡើងអានសារណារបស់ឈ្មោះដូ ណាណា

បានស្តាប់ចម្លើយរបស់ឈ្មោះសេង យៀន ជាដើមចោទនិងជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា : មុនដំបូងខ្លួនពុំបានដឹងថា ក្រុមហ៊ុន STAR BEAUTY នោះមានអ្នកណាខ្លះ ហើយក៏មិនដឹងអ្នកណាជាបណ្ណាធិការទី១ ទី២ ទី៣ ដែរ ព្រោះខ្លួនស្គាល់តែលោកដូ ណាណា ម្នាក់ប៉ុណ្ណោះដែលជា អ្នកពិភាក្សាមុខទំនិញអាណូត នេះ តថ្លៃគ្នារួចឈានដល់ការព្រមព្រៀងគ្នាធ្វើកិច្ចសន្យាចុះហត្ថលេខាជាមួយគ្នា ក្រោយ មកគាត់បានណែនាំខ្លួនឱ្យស្គាល់ឈ្មោះតុង ហូត និងជា លីម ថាជាម្ចាស់ភាគហ៊ុននៃក្រុមហ៊ុនSTAR BEAUTY ដែរ ហើយគាត់ទៅស្រុកបារាំងទៅ ។ ទៅដល់បារាំងគាត់សរសេរសំបុត្រឱ្យខ្លួនជាបន្តបន្ទាប់ និងទូរស័ព្ទមកខ្លួនថែមទៀត ដើម្បីឱ្យខ្លួនយល់ព្រមចុះហត្ថលេខាលើកិច្ចសន្យាជាមួយឈ្មោះ តុង ហួត និង ជា លឹម ព្រោះគាត់ជាប់រវល់ ។ ហើយខ្លួនសូមបញ្ជាក់ថាឈ្មោះដូ ណាណា មិនមែនជាសាក្សីទេ គឺជាបុគ្គលិកក្នុងភាគី (ក) ដែលមានភាគហ៊ុនក្នុងក្រុមហ៊ុន STAR BEAUTY ពិតប្រាកដ និងដែលជាអ្នកប្រព្រឹត្តខុសកិច្ចសន្យា ហើយឈ្មោះដូ ណាណា លួចដឹកទំនិញដែលសមត្ថកិច្ចតុលាការកំពុងហាមឃាត់យកចេញទៅចូលក្នុងបន្ទាយយោធាយុទ្ធភូមិភាគពិសេសនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩៨ ទាំងថ្ងៃត្រង់ ។ ក្នុងរឿងនេះ ក៏មានសាក្សីដែលបាននាំទិញនោះមកឃាត់ទុកក្នុងតុលាការក្រុងភ្នំពេញ ហើយមានលោកព្រះរាជអាជ្ញា ឈិន ជីវ៉ា ជាអ្នកទទួលឃាត់ទំនិញដែលលោក ដូ ណាណា បានលួចដឹកចេញរំលោភលើដីកាសម្រេចតាមពាក្យសុំរបស់តុលាការក្រុងភ្នំពេញ ។

<u>សំណូមពររបស់ខ្លួនគឺ</u> ៖

១- បដិសេធសារណារបស់លោកសោម ច័ន្ទឌីណា មេធាវីតំណាងការពារឱ្យឈ្មោះដូ ណាណា ។

២- តម្កល់សាលដីការបស់តុលាការសាលាឧទ្ធរណ៍

៣- ឃាត់ខ្លួនឬ ដកលិខិតឆ្លងដែនរបស់លោកដូ ណាណា និងលោតុង ហួត ជាបណ្តោះអាសន្ន ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី សោម ច័ន្ទឌីណា ការពារឱ្យចុងចម្លើយ និងជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលសនាការថា : នៅថ្ងៃទី ២៥-០១-៩៧ ឈ្មោះ តុង ហួត, ជា លីម និង ដូ ណាណា បានចុះលក្ខន្តិកៈបង្កើតក្រុមហ៊ុនមួយឈ្មោះSTAR BEAUTY អាហារ័ណ នីហារ័ណ ដែលមានទីតាំង នៅផ្ទះលេខ ៨$E_1$ ផ្លូវកម្ពុជាក្រោម សង្កាត់ផ្សារថ្មីទី២ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ក្នុងនេះមានឈ្មោះតុង ហួត ៤០ភាគហ៊ុន ទទួលងារជាបណ្ណាធិការក្រុមហ៊ុនឈ្មោះជា លីម មាន៣០ភាគហ៊ុន ជាសមាជិកក្រុមហ៊ុនឈ្មោះដូ ណាណា មាន៣០ភាគរយ ជាសមាជិកក្រុមហ៊ុន ។ នៅថ្ងៃទី ០៦-០៣-៩៧ ឈ្មោះតុង ហួត ដែលជាបណ្ណាធិការក្រុមហ៊ុន បានចុះកិច្ចសន្យាជាមួយឈ្មោះ សេង យៀន ដែលជាប្រធានក្រុមហ៊ុនទឹកអប់ ៤០២ ស៊ូលីម៉ាដាម ដោយចុះកិច្ចសន្យាប្រគល់ទំនិញផ្តាច់មុខម៉ាកចំនួន១២មុខ ទៅឈ្មោះសេង យៀន និងចុះកិច្ចសន្យាទទួលប្រាក់កក់ និងធានាដោយមានឈ្មោះ ង៉ាន់ ហ៊ាន, ជា លីម, ដូ ណាណា ដឹងឮជាសាក្សី ។ ហើយហេតុផល និងសន្និដ្ឋាន មាន :

១-ក្នុងលក្ខន្តិកៈក្រុមហ៊ុន STAR BEAUTY មានឈ្មោះតុង ហួត ជាបណ្ណាធិការ

២-អំពីពាក្យបណ្តឹងរបស់ឈ្មោះ សេង យៀន តាមកិច្ចសន្យាមិនអាចលើកយកមកដោះស្រាយបានទេ ព្រោះជាបណ្តឹងខុសបុគ្គលដែលត្រូវទទួលខុសត្រូវ ។

៣-បើភាគីចុះកិច្ចសន្យាគឺជាឈ្មោះ តុង ហួត ហេតុអ្វីបានជាប្តឹងពីឈ្មោះដូ ណាណា

៤-រីឯឈ្មោះ ង៉ាន់ ហ៊ាន, ជា លីម, ដូ ណាណា គឺគ្រាន់តែជាសាក្សីដឹងឮ ចុះហេតុអ្វីបានជាត្រូវទទួលខុសត្រូវសំណង ។

៥-ហេតុអ្វីបានជាឈ្មោះសេង យៀន ជ្រើសរើសយកតែឈ្មោះ ដូ ណាណា ។

<u>**សណ្ឋមពរៈ**</u>

ចាត់ទុកបណ្តឹងរបស់ឈ្មោះ សេង យៀន ចុះថ្ងៃទី ០៣-០៥-៩៨ ទុកជាឥតបានការដោយខុសនឹងទម្រង់ច្បាប់ ។

-សុំទាមទារឱ្យឈ្មោះសេង យៀន បង់ជម្ងឺចិត្ត ដែលប៉ះពាល់ដល់កិត្តិយស ពេលវេលាសាហ៊ុយចំនួន ១០.០០០ដុល្លាអាមេរិក ដល់ឈ្មោះដូ ណាណា ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ទៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់លោក សោម ច័ន្ទឌីណា តំណាងឱ្យលោកដូ ណាណា ចម្លើយរបស់លោកសេង យៀន និងសេចក្តីសន្និដ្ឋានរបស់មេធាវីចុងចម្លើយ.

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ៩៦ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៩៩ របស់លោកដូ ណាណា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី ។

-យល់ឃើញថា ការលើកឡើងរបស់លោកដូ ណាណា ក្នុងសារណាចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ១៩៩៩ ថា: លោកគ្រាន់តែជាសាក្សីដឹងឮ ក្នុងកិច្ចសន្យាចុះថ្ងៃទី ០៦-០៣-៩៧ លក់ទិញផ្ដាច់មុខរវាង ក្រុមហ៊ុន ស្ដាប៊ីយូពី និងហាងទឹកអប់ ៤០២ ហ្សុលីម៉ាដាម តែប៉ុណ្ណោះ ដូច្នេះលោកពុំទទួលខុសត្រូវក្នុង ការខាតបង់អ្វីទាំងអស់នោះ គឺជាការពុំត្រឹម ត្រូវឡើយពីព្រោះថា :

+ លោក ដូ ណាណា ជាសមាជិកភាគហ៊ុនសកម្មម្នាក់ បានដឹងច្បាស់ពីការងារកេស៊ីរបស់ក្រុមហ៊ុន ខ្លួន លោកក៏បានទទួលស្គាល់ដែរថា លោកបានធ្វើសាក្សីដឹងឮក្នុងការលក់ទំនិញផ្ដាច់មុខនេះ ម្យ៉ាងទៀត លោកបានធ្វើលិខិតប្រគល់សិទ្ធិចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៩៧ ប្រគល់សិទ្ធិលក់ផ្ដាច់មុខនូវមុខទំនិញ ក្រែមអាណូត ឱ្យហាងទឹកអប់ ៤០២ ហ្សាលីម៉ាដាម កំណត់រយៈពេលមួយឆ្នាំ ហើយរយៈពេលនេះក៏ពុំ-ទាន់ផុតកំណត់នៅឡើយ នេះជាការរំលោភលើកិច្ចសន្យាពិតប្រាកដ ។

+ ក្នុងពេល ដែលក្រុមហ៊ុនរបស់ខ្លួនកំពុងជាប់កិច្ចសន្យាជាមួយហាងទឹកអប់៤០២ ហ្សូលីម៉ាដាម លោកដូ ណាណា និងលោកតុង ហួត បានឃុបឃិតគ្នាបង្កើតក្រុមហ៊ុនហែលប៊ីយូធី ដែលមានលោកដូ ណាណា ជាបណ្ណាធិការទី១ លោកតុង ហួត ជាបណ្ណាធិការទី២ ហើយលោកទាំងពីរក៏បាននាំទំនិញចំនួន ១២មុខ ម៉ាក្សអាណូត មកលក់ដូចគ្នានឹងហាងទឹកអប់៤០២ ហ្សូលីម៉ាដាម ពិតប្រាកដមែន ។

+ ផ្អែកតាមលិខិតបញ្ជាក់ជូនចំពោះតុលាការគ្រប់លំដាប់ថ្នាក់ ចុះថ្ងៃទី២៤-០២-១៩៩៩ លោក តុង ហួត បានទទួលស្គាល់ថា ខ្លួនលោក និងលោកដូ ណាណា បានបើកក្រុមហ៊ុន ប៉ែលប៊ីយូអ៊ី នឹងបាននាំទំទិញម៉ាក្សអាណូតពីប្រទេសបារាំង កាលពីថ្ងៃទី២០-០៤-៩៨ មករំលោភលើកិច្ចសន្យាចុះថ្ងៃ ទី ០៦-០៣-៩៧ រវាងក្រុមហ៊ុនស្ដាប៊ីយូធី និងហាងទឹកអប់៤០២ ហ្សុលីម៉ាដាម ពិតប្រាកដមែន ។

-យល់ឃើញថា ការដែលមេធាវីលោកដូ ណាណា លើកឡើងថា បណ្ដឹងដើម របស់ដើមចោទពុំត្រឹមត្រូវនោះ ហើយកូនក្ដីលោកពុំជាប់កាតព្វកិច្ច និងកិច្ចសន្យាចុះថ្ងៃទី០៦-០៣-៩៧ នោះជាការភ័ន្តច្រឡំ ពីព្រោះអ្នករំលោភកិច្ចសន្យា ចុះថ្ងៃទី០៦-០៣-៩៧ គឺលោកដូ ណា និងលោកតុង ហួត ដែលបង្កើតក្រុមហ៊ុនថ្មីមួយទៀតពីក្រុមហ៊ុន ហែលប៊ីយូធី ហើយនាំមុខទំនិញដដែលមកលក់ដោយ គ្មានការយល់ព្រមពីហាងទឹកអប់ ៤០២ ហ្សុលីម៉ាដាម ដូច្នេះការដែលតុលាការថ្នាក់ក្រោមសម្រេចឱ្យ លោកទាំងពីរនេះ រួមគ្នាសងនោះ ជាការត្រឹមត្រូវហើយ ។

-យល់ឃើញថា សាលដីកាវជ្ឈប្បវេណីលេខ៨៦ ចុះថ្ងៃទី២៦-០២-៩៩ របស់សាលាឧទ្ធរណ៍ ដែលបាន សម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**និច្ឆ័យសេចក្តីចំពោះមុខលោក សេង យឿន កំបាំងមុខលោកដូ ណាណា**

**ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១- ទទួលបណ្តឹងសាទុក្ខលេខ ៩៦ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៩៩ របស់លោកដូ ណាណា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាវជ្ឈប្បវេណីលេខ ៨៦ ចុះថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទុក ជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តី ដែលលោកដូ ណាណា បានបង់រួចហើយ នៅតុលាការកំពូល ចំនួន ១៩.០០០រៀលគឺ ៖

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន ៩.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហើបប្រាក់

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ។

បង្គាប់ឱ្យលោកដូ ណាណា និង លោកតុង ហួត បង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការ-ក្រុងភ្នំពេញ ។

៥- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ១៩៩៩ ។